# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៨ សសរ

## សេចក្តីសំរេច
### ស្តីពីការបង្កើតក្រុមការងារ
### សំរាប់រៀបចំ គោលនយោបាយអភិវឌ្ឍន៍ថាមពល និងឧស្ម័នជាតិ
### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១:** បង្កើតក្រុមការងារមួយសំរាប់រៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល និងឧស្ម័នជាតិ ដែលមានសមាភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៣. | ឯកឧត្តម ឆាន់ សាផាន់ | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៤. | ឯកឧត្តម សារ៉ាក់ ខាន់ | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៥. | ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦. | ឯកឧត្តម ទី នរិន្ទ | ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា | សមាជិក |
| ៧. | ឯកឧត្តម តែ ដួងតារា | អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| ៨. | ឯកឧត្តម សយ សុខា | អគ្គលេខាធិការក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |

www.pheakdeylaw.com

៩. លោក ចាន់ សុជាវ៉ាត់ អនុប្រធាននាយកដ្ឋានផែនការយុទ្ធសាស្ត្រ និងគំរោងការ នៃក្រុមហ៊ុនអគ្គិសនីកម្ពុជា សមាជិក

១០. តំណាងសមាគមន៍កិច្ចព្រមព្រៀងប្រេងកាតមានលក្ខខ័ណ្ឌ (CPAA) សមាជិក

១១. តំណាងប្រតិបត្តិករសម្បទានិកនៃតំបន់ប្រេងកាតផែនសមុទ្រកម្ពុជា សមាជិក

១២. តំណាង Consortium (Siemens, Unocal and Egco) សមាជិក

**ប្រការ ២:** ក្រុមការងារនេះមានភារកិច្ច :

- រៀបចំកសាងឯកសារគោលនយោបាយ សំរាប់ការអភិវឌ្ឍន៍ថាមពលអគ្គិសនី និង ឧស្ម័នជាតិ ។
- សំរបសំរួលការពិគ្រោះយោបល់ក្នុងភាពជាដៃគូ រវាងស្ថាប័នរាជរដ្ឋាភិបាលជាមួយផ្នែកឯកជន ។
- វាយតំលៃអំពីសមត្ថភាពផ្គត់ផ្គង់ឧស្ម័នដល់រោងចក្រផលិតថាមពលអគ្គិសនី សំរាប់ដំណើរការបញ្ជូន និង ចែកចាយអគ្គិសនីតាមខ្សែបណ្តាញបញ្ជូនអគ្គិសនីភាគខាងត្បូង ។
- ផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីលក្ខខ័ណ្ឌបច្ចេកទេស ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ច្បាប់ និងលក្ខខ័ណ្ឌផ្សេងៗទៀត សំរាប់ការជំរុញការអភិវឌ្ឍន៍ ថាមពលអគ្គិសនី និងឧស្ម័នជាតិ ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាលទៅតាមដំណាក់កាលការងារនីមួយៗ ។

**ប្រការ ៣:** ប្រធានក្រុមការងារមានសិទ្ធិជ្រើសរើសសមាជិកមួយរូបទទួលចាត់ចែងការងារជំនួសក្នុងពេលអវត្តមាន ។

**ប្រការ ៤:** សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ប្រធាននិងសមាជិកក្រុមការងារ ដែលបានរាយនាមក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៥៧ ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥(ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com


UNOCAL 76
CASE 13A (modified)
HO CHI MINH
O MON
5 km-26"
TRA NOC
SOC TRANG
110 km-26"
HON DAT
AN MINH
40 km-16"
CA MAU
KAMPOT
260 km-26"
UNOCAL
BLOCK B
VIETNAM
CAMBODIA
ENTERPRISE
CANADIAN PETROLEUM
PEDCO
OPECO